Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 3/2 (April 2002): 100–111



# Responding to The Rape of Cambodian Children

*Steve GOURLEY*

Every day of every year, in the villages and communities of Cambodia, children as young as three are sexually assaulted. Many are tricked or sold into prostitution; others end up working in brothels as a result of desperate poverty or similar overwhelming problems. What is not as widely known, however, is that countless more children from all walks of life are being raped in their own homes, villages, and communities, to the extent that rape has perhaps become the most common threat to the well-being of Cambodian children today. Consider these statistics compiled by LICADHO, a non-political, non-religious human rights organization working in fourteen provinces across Cambodia:[1] more than half (60%) of all the cases investigated by LICADHO's child rights department in 1999 and 2000 were rape and indecent assault. *The average age of victims was only twelve, while nearly one-fourth (23%) were committed against children under*

[1]Portions of this article have been taken directly from the report "Crimes in the Community: Rape and Indecent Assault in Cambodia" by Diane O'Connell, published in 2001 by The Cambodian League for the Promotion and Defense of Human Rights—LICADHO.

*ten; the youngest had only reached her third birthday.* In 2001 the situation did not improve, with rape and indecent assault continuing to be the highest reported child rights violation (126 cases), followed by physical abuse/torture (48 cases), trafficking (buying and selling children—16 cases) and murder (15 cases).

These statistics refer to the number of cases investigated by LICADHO, and do not prove that the rape of children is on the rise in Cambodia. However, they do indicate that 1) sexual assault of children is not limited to commercial sexual exploitation, and 2) the rape of children in their own homes and communities is a serious issue affecting children all over the country. It may also be true that, since many cases doubtless go unreported, the statistics indicate a growing threat to Cambodia's children. Any such growth could be fueled in part by the increasing availability of pornography (both printed and video), as many perpetrators involved in cases investigated by LICADHO claimed they had watched or were acting out pornographic images they had viewed.

What is clearer is that rape affects children of all ages and from every ethnic, social, and economic background. Those who are most at risk include street children, stepchildren, "adopted" children, physically and mentally handicapped children, and those in prison. However, LICADHO's experience indicates that any child—not only the poor or vulnerable—can become a victim of rape.

If then this is a serious threat to our children, what should we do? Will we allow the rape of our daughters, sisters, and nieces (and in some cases sons and nephews) to continue? What should be our response as Christians, and as parents, family, and community members? This is a difficult question, but we can all begin by being *informed* of the issue, *sensitive* to survivors, and *proactive* in protecting and supporting children.

## Be Informed

*"Get wisdom, get understanding; do not forget my works or swerve from them. Do not forsake wisdom, and she will protect you; love her and she will watch over you."*[2] As Christians, we are called to seek out knowledge and understanding in order to know the Lord's will and to know how to live safely and wisely in this world. Therefore, the first step in responding to the rape of children is to become well-informed about the issue.

## What is Rape?

Because rape is a crime involving sexual acts, it is rarely discussed openly and in detail. As a result the definition of rape is often not understood, even among police and other authorities. Article 33 of the Cambodian Penal Code, adopted in 1992 during the UNTAC period, states:

> *"Rape is any sexual act involving penetration against a non-consenting person".*

Although not specifically defined, the word "penetration" here refers to the insertion of a person's penis, finger, other body part, or other object, into another person's vagina or anus. The degree of penetration (whether deep or shallow) is unimportant; if any penetration has occurred without consent, then a rape has taken place. If a person intends to commit penetration and is unsuccessful for any reason, he is guilty of attempted rape, which is equally punishable by Article 33.[3]

---

[2]Prov 4:5–6.

[3]*Indecent Assault,* on the other hand, is a separate crime, defined by Article 42 of the Penal Code as "*touching, caressing or any other sexual act not involving penetration*". Here it is understood that the intention was not to penetrate, therefore such an act would not be considered rape or attempted rape. Indecent assault is still a crime, however, punishable by imprisonment of 1–3 years.

## Types of Rape Violations

Rape can occur with a variety of attendant circumstances:

1) *Sexual Assault with Violence, Threat, or Weapons:* This is rape accompanied by violence such as beating, torture, etc., or the use of verbal threats or weapons to intimidate the victim. These cause further trauma to the victim, and thus can result in harsher penalties for perpetrators.
2) *Rape and Murder:* In some cases rape victims are killed either as a result of the physical abuse caused by the act, or in order to protect the perpetrator from arrest. In one case investigated by LICADHO, a four-year-old girl was raped and murdered.
3) *Gang Rape:* A gang rape is one involving three or more perpetrators, again inflicting severe trauma on the victim. Human rights workers believe such cases are on the increase, again possibly because of the wider availability of pornography and/or the growing number of gangs in Cambodia.
4) *Rape Involving Accomplices:* There appears to be a growing number of women who actively help their husbands, boyfriends, and others trick young girls so that they can be easily raped, possibly in order to prevent these men from going to prostitutes and later infecting their wives or girlfriends.

## Who Are The Perpetrators?

Just as children of all ages and backgrounds can be victims of rape, perpetrators also come from all ages, occupations, and roles in communities. As in child trafficking (buying and selling children for labor, sexual, or other purposes), perpetrators often know the child beforehand, coming from within the family (fathers, uncles, or even brothers), or from within the child's community, such as neighbors or others working nearby. Even the church—both its members and its leaders—is not exempt from harboring potential or actual rapists, and must take steps to safeguard its members. A majority of cases

investigated by LICADHO[4] have been farmers or fishermen, (30%), followed by government employees (police, soldiers, or MPs, 17%), "other" occupations (landlords, moto-drivers, doctors, goldsmiths, etc., 14%). Disturbingly, a significant number of rapists are students (14%), with some as young as thirteen. Combined with the fact that the average age of perpetrators was twenty-five, this indicates that parents, schools, and churches need to give serious and immediate attention to instructing boys and young men about respecting girls and women.

## Laws and Penalties Against Rape

In Cambodia, rape is a criminal offense punishable by law. As such, victims and their families have the right to file criminal charges against perpetrators, both in order to provide justice to the victim as well as to protect other women and children from being raped in the future. Persons found guilty of rape are punishable by imprisonment. According to Article 33 of the Penal Code, punishments for rapists include the following:

*Minimum Punishment:* 5-10 years imprisonment
*Rape Accompanied by Fraud, Violence, or Threat:* 10–15 years imprisonment
*Rape Committed by a Person in a Position of Authority over the Victim (such as police, employer, etc.):* 10–15 years imprisonment
*Rape against a Minor (person under 16 years old):* Double the above prison term(s).

## Be Sensitive

Because it is such a little discussed and understood topic, there are many misunderstandings about the causes of rape and its impact on its victims. Thus many people (even parents) often accuse victims of doing something to cause or allow the rape to occur. As a result they are also insensitive to the feelings and needs of survivors, and

[4]Unless otherwise indicated, all statistics are compiled from cases investigated by LICADHO during 1999 and 2000.

deny them the support they need to recover. As Christian parents, relatives, or church and community members, we of all people should be understanding and compassionate to victims, and know how to appropriately support them. This begins with understanding some of the incorrect beliefs people have about rape and its impact on women and children.

## Four Myths regarding Rape

**Myth #1: Women provoke rape by suggestive dress, provocative behavior, being alone at night, etc.**
*Truth: No type of dress or behavior gives a man the right to sexually assault a women or child.*
This myth wrongly shifts the blame from the perpetrator to the victim, and ignores the fact that young children who are raped do not yet possess the maturity to intentionally dress or behave provocatively.

**Myth #2: Men are unable to control their sexual desires, making rape a spontaneous assault.**
*Truth: Studies in the United States and England show that most rapes are entirely or partly planned, with only 15% being spontaneous.*
While many believe that rapists are sexually starved, these studies also show that many perpetrators are either married or involved in consenting relationships with girlfriends, prostitutes, etc.

**Myth #3: Most rapists are strangers to their victims.**
*Truth: The majority of rapes are committed by people known to the victim.*
Of the cases investigated by LICADHO, 68% were committed by someone who knew the victim well (relatives or others living in the household, boyfriends, neighbors, and friends), while only 25% were committed by casual acquaintances or strangers.

**Myth #4: Many women falsely accuse men of rape.**
*Truth: Rape is one of the most under-reported of all serious crimes.*
A study in the US indicated that only 2% of reported rapes were false claims. In Cambodia, it is also unlikely that a women or

> child would make a false accusation of rape for three reasons: 1) the shame and embarrassment associated with rape and sexual activity in Khmer culture make it embarrassing to admit to family and friends, and put her reputation and chances of marriage at risk; 2) the insensitive treatment of rape cases by authorities make it a difficult experience to file charges; and 3) fear and mistrust of the legal system cause many women to believe they will not receive justice. In light of these difficulties, it is unlikely that a Cambodian woman or girl would lie about a rape.[5]

Because of the above myths, accusations of rape are often not taken seriously within the family, the village or community. However, the fact is that *rape is an inexcusable crime and grievous sin against God.*

**The Impact of Rape on Victims**

*This is the true story of "Thany" (all names of persons appearing in case studies have been changed):*

*In 1999, seven-year-old Thany was invited to play at her neighbor's house by another young girl named "Dara." She was reluctant to go, and said later that Dara's thirteen-year-old brother had raped Thany on at least three prior occasions. Urged by her mother, Thany went with Dara to play. After playing for a while, Dara suggested they go to the pond to wash, and when they finished washing, Thany rushed to go home, but Dara called to her brother that Thany was getting away.*

*The brother came and caught Thany, covered her mouth and dragged her to some nearby palm trees. He then told Dara to go get a mat and three kramas (scarves). Then the boy called over two of his friends, aged twelve and thirteen. Once Dara laid out a mat, the three boys forced Thany to lie down on it and tied a scarf around her mouth,*

---

[5]While thus statistically unlikely that a Cambodian woman would falsely accuse a man of rape, it could happen. Here as elsewhere, any defendant should be presumed innocent until proven guilty, and allowed his or her day in court [ed.].

*then tied her hands to the end of a piece of wood which they laid across her chest. They tied her legs apart, then each boy proceeded to rape her, two times each. While this was going on, Dara was sitting a short distance away watching and keeping look out.*

*The boys then took Thany to the pond and again tied her and raped her two times each. Thany was traumatized by the ordeal and has experienced emotional problems since then. She also suffered injuries to her genital area which required medical treatment. LICADHO investigators intervened to get the police to arrest the boys, who until then were still living freely in the village near to the victim. During the investigation it was discovered that the three boys had been watching pornography at a local video bar, and it appears they copied actions they had seen on video.*

Think for a moment about how you would feel if you were Thany: 1) during the rape, 2) after the rape, and 3) while telling family members, police, and the court about the experience. How would you think about yourself, the perpetrators, the friend who had betrayed you, and your future?

Perhaps because of the myths described above and the disturbing nature of the crime, many people do not reflect deeply on how a rape victim may feel. As a result there is a serious lack of understanding about the traumatic effects of sexual assault on the life of a victim. All parts of society must be educated as to the physical and psychological impacts of rape on women and children such as Thany. These can include the following:

**1. Physical Effects**

- Physical injury inflicted by the assailant
- Possible infection of HIV/AIDS
- Other sexually transmitted diseases (gonorrhea, syphilis, herpes simplex, urinary tract infections and polyps)
- Unwanted pregnancy, or pregnancy in very young girls
- Nausea, fatigue, tension headaches, abdominal pain, and vaginal pain.

**2. Psychological Effects**

- Severe anxiety, fear, depression, guilt, self-blame, loneliness, anger, aggressiveness
- Humiliation, shame, embarrassment, lack of self-confidence, helplessness
- Decrease in appetite; chronic bed-wetting,
- Self-mutilation
- Suicide

*In 2002, Chenda, an eight-year-old girl was raped twice by a neighbor who told her not to tell anyone or else he would kill her. One day when her mother was bathing her, she noticed something was wrong and questioned her daughter. When Chenda refused to tell her, both her mother and father beat her with an electric cord. She then admitted she had been raped, and was terrified the man would find out and hurt her. Her family says that she is now very scared of other people as well, and would like her to receive counseling to overcome this.*

*In 2001, Sophal, a seven-year-old girl, was severaly raped, beaten, and locked in a secret location for several days. When she was found, she was unconscious because she had lost so much blood, and needed emergency hospitalization. Currently she has nightmares and wets her bed at night, is afraid of people (especially men), is scared to go anywhere without her mother, and therefore has not been attending school. When playing with her brothers and sisters, she can suddenly become angry and aggressive. Counsellors who have been meeting with Sophal note that if she is not given the opportunity to talk about and express her feelings about being raped, she will express them in other ways, for example in her play.*

*In 2000, Sophea, a fifteen-year-old girl, was gang raped by fourteen young gang members in her village. She was severely beaten during the rape, resulting in bruises and internal injuries to her genitals. After the experience, Sophea suffered recurring nightmares, intense fear of being alone, and bouts of crying.*

Long-term effects of rape may include personality changes, lack of trust, pessimism about the future, loss of confidence, and distrust

of adults. Community relationships also are affected, as girls who lose their virginity in Khmer culture suffer greatly damaged reputations, putting them at risk of discrimination by friends and neighbors, and greatly reducing their chances of marriage. Studies have also found that rape victims are at a much higher risk of being raped again or to be sold or coerced into prostitution than other girls in the community.

These are clearly life-altering effects upon the victim, and also impact the victim's family. However, even if the above effects are not immediately apparent, it does not necessarily mean they are not there or that she is recovering well. She may be repressing (trying to forget) the experience, or hiding her feelings for fear of being misunderstood. In any case, it is important that we as family, community, and church members are aware of what survivors such as Thany may be experiencing, and show unconditional Christian love, acceptance, and support.

## Be Proactive

To be "proactive" means that you take action to prevent problems before they happen, or if a problem has already occurred, to take personal responsibility for solving it to the best of your ability. With such a sensitive and disturbing issue as child rape, it is easier to deny or ignore it rather than to confront it and become involved in protecting children. But as Christians called to engage with and minister to the world, we are to be proactive and address the holistic needs of children and adults. Blessed with wisdom, spiritual gifts of various kinds and, most of all, love, we have already been equipped by God to respond to the issue of child rape. And all of us, in our roles as parents, relatives, church, or community members, can be proactive in the following ways:

**Parents and Families:**

- Discuss with your daughters, in a way appropriate for their age and understanding, about the problem of sexual abuse. Let them know that it is not right for any adult to touch or molest them sexually, to be wary of going alone to quiet places,

and to run for help if they fear they will be molested in any way.

- Let them know that they are always free to talk to you about their problems, and that if they are ever raped you will be there to love, listen and support them unconditionally.
- Know and watch for any physical or psychological signs that your child has been raped (as listed above), and if you suspect they have been, gently provide them the opportunity to tell you. Do not force them, as this may add to the trauma. Eventually they will tell you or another person they trust if given enough opportunities.
- Consider, after discussing with your child, reporting the incident to the police, the Ministry of Women and Veteran's Affairs, human rights groups such as LICADHO, or other NGOs such as the Cambodian Women's Crisis Centre.[6] Filing a complaint may lead to the arrest of the perpetrator and prevent other children from suffering the same experience.

**Churches:**

- Inform church members of the problem by sharing, in an appropriate way, time and place, the myths, truth, and impacts of rape on both women and children. Reading portions of this article in a small women's group, for instance, and then discussing, is one way to do this.
- Show Christian love and support of various kinds to survivors of rape. Do this without gossiping of their experience or embarrassing them; simply showing the child you love and

---

[6] National Police Hotline: 023 720555; World Vision Nevea Thmey Centre: 023 880342; Cambodian Women's Crisis Centre: 023 982158 or 012 840507; LICADHO: Phnom Penh: 023 360965/217626; Banteay Meanchey: 054 958861; Battambang: 053 952828; Koh Kong: 035 936116; Kg Cham: 042 941464; Kg Chhnang: 026 988637; Kg Speu: 025 987220; Kg Thom: 062 961292; Kompot: 033 932663; Prey Veng 043 944527; Pursat: 052 951496; Siem Reap: 063 964066; Sihanoukville: 034 933716; Svay Reang: 044 945833; Takeo: 032 931360.

value them is enough in most cases. In this way they will know the church is a place of healing and acceptance, and experience the love of God through their church family.

**Communities:**

- Inform your neighbors, community leaders and local authorities of the problem by sharing, again in an appropriate way, the myths, truth, and impacts of rape. After they understand the issue they can join with you in protecting and supporting children.
- Watch out for the children in your community, taking care that they do not place themselves at risk by going alone to distant or quiet places, or by hanging out with suspicious men or youth.
- If you hear that a child has been raped, discuss privately with the child and her parents about reporting the incident to the police, a human rights organization like LICADHO or another NGO working with women or children. Let them know that legal and social assistance is available through them, and encourage them to seek justice and protect other children by filing charges against the perpetrator.
- Again and most importantly, show love and acceptance to survivors in your community by not gossiping about their experience or treating them in any way which would embarrass or demean them. Value them as you would value any child, for God loves all children unconditionally, no matter what they have experienced.

In conclusion, as Christians with wisdom, gifts and faith, we of all people can—and should—be proactive in protecting our children from falling victim to rape, and in loving and supporting victims in their recovery. If we are *informed, sensitive* and *proactive*, and involve the Lord in our efforts, we *can* do this by his power and grace.

សំណុំធិកឃ្មុំ ៣/២ (មេសា ២០០២): ១១២-១៣៣



# ការឆ្លើយតបចំពោះ ការចាប់រំលោភ កុមារកម្ពុជា

*លោក ស្មីវ ហ្គ័រលី*

រៀងរាល់ថ្ងៃជាប្រចាំឆ្នាំ នៅតាមភូមិ និងនៅតាមសហគមន៍នៃប្រទេសកម្ពុជា កុមារដែលនៅវ័យក្មេងអាយុបានប្រមាណជាបីឆ្នាំ ត្រូវទទួលរងនូវការចាប់រំលោភយ៉ាងព្រៃផ្សៃជាទីបំផុត ។ កុមារជាច្រើនត្រូវចាញ់បោកគេ ឬគេយកទៅលក់នៅក្នុងផ្ទះបនស្រីពេស្យា កុមារដទៃទៀតត្រូវបង្ខំចិត្តធ្វើការនៅតាមផ្ទះបន ដោយព្រោះតែភាពទីទ័លក្រតោកយ៉ាកយ៉ាងខ្លាំង ឬក៏មានបញ្ហាយ៉ាងលំបាកស្រដៀងគ្នានេះឯង ។ ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលគេមិនបានដឹងទូលំទូលាយជាងនេះទៅទៀតនោះ គឺថាមានកុមាររាប់មិនអស់មកពីគ្រប់ស្រទាប់វណ្ណៈទាំងអស់ ដែលកំពុងទទួលរងនូវការចាប់រំលោភនៅក្នុងផ្ទះ នៅក្នុងភូមិ និងនៅក្នុងសហគមន៍របស់ខ្លួនផ្ទាល់ ចំពោះទំហំនៃការចាប់រំលោភនោះ ប្រហែលអាចក្លាយទៅជាការគំរាមគំហែងដ៏សាមញ្ញបំផុតដល់សុខមាលភាពរបស់កុមារកម្ពុជាទៅហើយសព្វថ្ងៃនេះ ។ សូមពិចារណាមើលពីការស្រង់ស្ថិតិ ដែលបានចងក្រងឡើងដោយអង្គការ *លីកាដូ* ដែលជាអង្គការគ្មាននិន្នាការផ្នែកនយោបាយ ផ្នែកសាសនា តែជាអង្គការសិទ្ធិ

មនុស្សស៊ុទ្ធសាធ ដែលបាននិងកំពុងធ្វើការនៅតាមបណ្ដាខេត្ត ១៩ នៅក្នុងប្រទេសកម្ពុជា[១] បានឲ្យដឹងថា៖ មានជាងពាក់កណ្ដាល (៦០%) នៃករណីទាំងអស់ដែលបានស៊ើបអង្កេតដោយនាយកដ្ឋានទទួលបន្ទុកផ្នែកសិទ្ធិកុមាររបស់អង្គការ *លីកាដូ* ។ នៅក្នុងឆ្នាំ ១៩៩៩ និង ឆ្នាំ ២០០០ កុមារត្រូវគេរំលោភ និងដោយអំពើអសីលធម៌ ។ *អាយុរបស់ជនរងគ្រោះគិតជា មធ្យមភាគគឺ១២ឆ្នាំតែប៉ុណ្ណោះ ហើយចំណែកចំនួនជិតតែមួយភាគបួន (២៣%) នៃកុមារទាំងនោះគឺត្រូវទទួលរងគ្រោះនៅក្រោមអាយុដប់ឆ្នាំ ហើយចំពោះក្មេងបំផុតនោះ គឺនៅពេលកុមារនោះទើបតែបានទទួលធ្វើពិធីខួបកំណើតបានតែបីដងប៉ុណ្ណោះស្រាប់តែត្រូវគេចាប់រំលោភទៅហើយ* ។ នៅក្នុងឆ្នាំ ២០០១ ស្ថានការណ៍នៅតែគ្មានភាពប្រសើរឡើងឡើយ ទាំងការចាប់រំលោភ និងការវាយប្រហារដោយអំពើអសីលធម៌នៅតែបន្តឥតឈប់ គឺឡើងខ្ពស់បំផុត តាមរបាយការណ៍ចំពោះការរំលោភលើសិទ្ធិកុមារ (១២៦ ករណី) ក្នុងនោះមានទាំងការធ្វើការរំលោភលើរូបរាងកាយ ឬការធ្វើទារុណកម្ម (៤៨ ករណី) ការជួញដូរមាន (១៦ ករណី) និងការសម្លាប់ចំពោះកុមារមាន (១៥ ករណី) ។

យោងតាមសំរង់ចំនួនស្ថិតិនៃករណី ដែលបានស៊ើបដោយអង្គការ *លីកាដូ* មិនបានបង្ហាញថាការចាប់រំលោភដល់កុមារកំពុងតែកើនឡើងនៅកម្ពុជានោះទេ ។ តែទោះជាយ៉ាងណាក៏ដោយ គេបានបង្ហាញឲ្យដឹងថា ទី១ ការចាប់រំលោភកុមារមិនមែនកំណត់ត្រឹមតែលើការកេងប្រវ័ញ្ចផ្នែកភេទតាមបែបធ្វើពាណិជ្ជកម្មនោះទេ ហើយទី២ ការចាប់រំលោភដល់កុមារនៅក្នុងផ្ទះ

---

[១] *ចំណែកខ្លះនៃអត្ថបទនេះបានដកស្រង់ផ្ទាល់ពីរបាយការណ៍មួយដែលមានឈ្មោះថា* " Crimes in the Community: Rape and Indecent Assault in Cambodia" *ដែលរៀបចំចងក្រងដោយ ដាយអាណោ អូ ខនណែល ដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០០១ ដោយ សម្ព័ន្ធកម្ពុជាសំរាប់ការលើកកំពស់ និងការពារសិទ្ធិមនុស្ស លីកាដូ ។*

និងក្នុងសហគមន៍របស់ខ្លួនផ្ទាល់នោះ គឺជាបញ្ហាធ្ងន់ធ្ងរដែលមានឥទ្ធិពលប៉ះពាល់ដល់កុមារទូទាំងប្រទេសតែម្តង ។ ប្រហែលវាអាចជាការពិតដែរ ដោយហេតុថាមានករណីជាច្រើនដោយឥតសង្ស័យ គឺមិនមានការរាយការណ៍ណាមួយនោះឡើយ ស្ថិតិទាំងនោះអង្គុលបង្ហាញថា មានការគំរាមជាខ្លាំងចំពោះកុមារកម្ពុជា ។ ការកើនឡើងនោះ គឺមានសន្ទុះលឿនឡើង ដោយសារតែការកើនឡើង ចំពោះរូបអាសភាស (ទាំងទស្សនាវដ្តី ទាំងវីដេអូ) តាមករណីរបស់ជនល្មើសជាច្រើនដែលអង្គការ *លីកាដូ* ស៊ើបអង្កេតបានមក នោះបានអះអាងថា គេបានមើល ឬបានយកត្រាប់តាមរូបភាពអាសអាភាស ដែលគេបានមើលនោះ ។

អ្វីដែលច្បាស់ជាងនេះគឺថា ការចាប់រំលោភមានឥទ្ធិពលលើកុមារគ្រប់អាយុ គ្រប់ជាតិពន្ធ គ្រប់សង្គមរស់នៅ និងគ្រប់ស្ថានភាពសេដ្ឋកិច្ចទាំងអស់។ អ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់ជាបំផុតនោះ គឺ ក្មេងអនាថា កូនចុង "កូនចិញ្ចឹម"កុមារដែលមានបញ្ហាលូតលាស់ខុសធម្មតាផ្នែករាងកាយ និងផ្នែកសិតិបញ្ញា និងកុមារដែលជាប់ក្នុងមន្ទីរឃុំឃាំង ។ ទោះបីជាយ៉ាងណាក៏ដោយ យោងតាមបទពិសោធន៍របស់អង្គការ *លីកាដូ* បានបង្ហាញឲ្យដឹងថា កុមារណាក៏ដោយមិនថាឡើយ កុមារនោះក្រីក្រ ឬងាយរងគ្រោះនោះទេ គឺអាចក្លាយទៅជាជនរងគ្រោះដោយសារការចាប់រំលោភតែទាំងអស់ហ្នឹង ។

បើសិនជាអ៊ីចឹងមែននោះ គឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរចំពោះកូនចៅរបស់យើង ចុះតើយើងត្រូវធ្វើដូចម្តេចទៅ? តើយើងអនុញ្ញាតឲ្យមានការចាប់រំលោភដល់កូនស្រី ប្អូនស្រី និងក្មួយស្រីរបស់យើង (ហើយករណីខ្លះទៀតនោះកូនប្រុស និងក្មួយប្រុសរបស់យើង) នៅតែបន្តទៅទៀតឬ? ក្នុងនាមយើងជាគ្រីស្តបរិស័ទ ជាឪពុកម្តាយ ជាគ្រួសារ និងជាអ្នករស់នៅក្នុងសហគមន៍ជាមួយគ្នា តើយើងគួរឆ្លើយតប ដោយរបៀបណា? នេះជាសំណួរមួយឃ្លាដែលពិបាកមែនទែន ប៉ុន្តែយើងទាំងអស់គ្នាអាចចាប់ផ្តើមដោយលើក

យកបញ្ហានោះ *មកបញ្ជាក់ឲ្យដឹងច្បាស់* គ្រប់គ្នា *យកចិត្តទុកដាក់* ចំពោះជនរងគ្រោះ និង *រិះរកមធ្យោបាយ* ត្រៀមទុកជាមុនដើម្បីការពារ និងគាំទ្រដល់កូនចៅរបស់យើង ។

## សូមជ្រាបជាពត៌មាន

*"ចូរខំឲ្យបានប្រាជ្ញា ចូរខំឲ្យបានយោបល់ កុំឲ្យភ្លេចឡើយ ក៏កុំឲ្យបែរចេញពីពាក្យដែលមាត់អញពោលដែរ កុំឲ្យចោលប្រាជ្ញាឡើយ នោះនឹងការពារឯង ចូរស្រឡាញ់ប្រាជ្ញាចុះ នោះនឹងបំរុងឯង"* ។[២] ក្នុងនាមយើងជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យស្វែងរកចំណេះដឹង និងយោបល់ ដើម្បីឲ្យយើងបានស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងស្គាល់នូវរបៀបរស់នៅដោយសុវត្ថិភាព និងដោយប្រើបញ្ញាក្នុងការរស់នៅក្នុងលោកីយ៍នេះ។ ដូច្នេះជំហានដំបូងក្នុងការឆ្លើយតបទៅនឹងការចាប់រំលោភដល់កុមារនេះ គឺត្រូវដឹងឲ្យបានច្បាស់ពីបញ្ហានេះ ។

### អ្វីទៅជាការចាប់រំលោភ?

ពីព្រោះការចាប់រំលោភ គឺជាបទឧក្រិដ្ឋមួយបែបដែលទាក់ទងនឹងការប្រព្រឹត្តិខាងផ្លែកផ្លូវភេទ បញ្ហានេះគឺជារឿងមួយដែលគេកម្រលើកយកពិភាក្សាជាចំហ និងនិយាយឲ្យបានក្បោះក្បាយណាស់ ។ ដោយហេតុនេះហើយ បានជានិយមន័យការចាប់រំលោភជាទូទៅពិបាកយល់ណាស់ សូម្បីតែក្នុងចំណោមនគរបាល និងអាជ្ញាធរមានសមត្ថកិច្ចក៏ពិបាកយល់ដែរ ។ នៅក្នុងមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា យោងតាមច្បាប់នៅក្នុងឆ្នាំ ១៩៩២ ក្នុងសម័យ *អ៊ុនតាក់* បានចែងថា៖ *"ការចាប់រំលោភ គឺជា*

---

[២] *សុភាសិត ៤:៥-៦*

*សកម្មភាពផ្លូវភេទណាមួយដែលទាក់ទងនឹងការចាប់រុញបង្ខំប្រឆាំងនឹងបំណងរបស់ភាគីម្ខាងទៀត"* ។

ទោះបីជាយ៉ាងណាក៏ដោយ គឺមិនបានបញ្ជាក់ពីអត្ថន័យយ៉ាងច្បាស់លាស់ឡើយ ចំពោះពាក្យដែលថា "ការរុញបង្ខំ" នៅត្រង់កន្លែងនេះ គឺនិយាយយោងទៅដល់ការយកប្រដាប់ភេទ ម្រាមដៃ អវយវៈដទៃទៀតរបស់មនុស្សណាម្នាក់ ឬវត្ថុអ្វីផ្សេងទៀត យកទៅញាត់ចូលទៅក្នុងប្រដាប់ភេទ ឬរន្ធគូថរបស់មនុស្សម្នាក់ទៀត ។ កំរិតនៃការរុញបញ្ចូលនោះ (មិនថា ឡើយរុញជ្រៅឬរាក់ប៉ុណ្ណានោះឡើយ) គឺមិនសំខាន់ទេ បើសិនមានការរុញបញ្ចូលកើតមានឡើងដែលផ្ទុយពីបំណងឆន្ទៈរបស់ភាគីម្ខាងទៀតនោះ គឺចាត់ទុកថាជាការចាប់រំលោភទៅហើយ ។ បើសិនជាមនុស្សម្នាក់ ព្យាយាមប្រព្រឹត្តនូវការរុញបញ្ចូល ហើយមិនបានសម្រេចដោយប្រការណាមួយ បុគ្គលរូបនោះត្រូវជាប់ពិរុទ្ធពីការមានបំណងបំពានមិនសមរម្យ ដែលសមនឹងទទួលទណ្ឌកម្មយោងតាមមាត្រា ៣៣ នៃច្បាប់ខាងលើ ។[៣]

## ប្រភេទនៃការចាប់រំលោភ

ការចាប់រំលោភអាចកើតឡើងតាមកាលៈទេសៈផ្សេងៗគឺ៖

១) *ការរំលោភបំពានផ្លូវភេទ ដោយអំពើហឹង្សា ការគំរាមកំហែង ឬដោយប្រើអាវុធ*: ការរំលោភនេះ គឺប្រព្រឹត្តស្របជាមួយការប្រើអំពើ

---

*[៣] ការបំពានមិនសមរម្យ ផ្ទុយទៅវិញ គឺជាបទឧក្រិដ្ឋដោយឡែកមួយដែលបានកំណត់ដោយមាត្រា ៤២ នៃច្បាប់ព្រហ្មទណ្ឌ ដូចជា "ការប៉ះពាល់ ការអង្អែលលេងប្រដាប់ភេទ ឬសកម្មភាពផ្លូវភេទដទៃណាទៀតដែលមិនទាក់ទងនឹងការរុញបញ្ចូលប្រដាប់ភេទ" ។ នៅត្រង់នេះគឺគេយល់ថា គោលបំណងនោះមិនមែនចង់រុញប្រដាប់ភេទចូលឡើយ ហេតុដូច្នេះហើយ ទង្វើបែបនេះគេមិនរាប់ថាជាការចាប់រំលោភ ឬការមានបំណងចង់ចាប់រំលោភឡើយ ។ តែទោះជាយ៉ាងណាក៏ដោយការនេះនៅតែគេចាត់ទុកជាបទឧក្រិដ្ឋមួយដដែល គឺត្រូវទទួលទោសជាប់ពន្ធនាគារ ១-៣ ឆ្នាំ ។*

ហិង្សា ដូចជាការវាយដំ ការធ្វើទារុណកម្មជាដើម ឬការប្រើពាក្យគំរាមកំហែង ឬអាវុធដើម្បីបំភិតបំភ័យដល់ជនរងគ្រោះ ។ មូលហេតុទាំងនេះ អាចបណ្តាលឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរថែមទៀតដល់ជនរងគ្រោះ ហេតុដូច្នេះហើយ វាអាចជាលទ្ធផលក្នុងការផាកពិន័យដល់ជនល្មើសឲ្យធ្ងន់ធ្ងរថែមទៀត ។

២) *ការចាប់រំលោភនិងការសម្លាប់* : នៅក្នុងករណីខ្លះៗជនរងគ្រោះដែលត្រូវគេចាប់រំលោភរួចហើយ ត្រូវស្លាប់ គឺអាចបណ្តាលមកពីការរងគ្រោះលើរូបរាយកាយនៅពេលចាប់រំលោភ ឬអាចបណ្តាលមកពីជនល្មើសធ្វើឡើងដើម្បីបំបាត់ដាន ។ នៅក្នុងករណីមួយដែលអង្គការ *លីកាដូ* ធ្វើការស៊ើបអង្កេតនោះ គឺក្មេងស្រីម្នាក់ អាយុ៨ឆ្នាំត្រូវគេចាប់រំលោភ ហើយគេបានសម្លាប់ចោល ។

៣) *ការចាប់រំលោភដោយក្រុមជើងកាង* : ការចាប់រំលោភបែបនេះ គឺជាការចាប់រំលោភដែលមានជនល្មើសពីបីនាក់ ឬច្រើនជាងនេះ ការនេះបណ្តាលឲ្យមានការប៉ះទង្គិចធ្ងន់ធ្ងរកាន់តែខ្លាំងឡើងទៀត ។ បុគ្គលិកសិទ្ធិមនុស្សជឿថាករណីបែបនេះគឺកំពុងតែកើនឡើង ប្រហែលដោយសារតែការរីកផុលផុសនៃរូបភាពអាសអាភាស និងការកើនឡើងនៃពួកបងធំនៅក្នុងប្រទេសកម្ពុជា ។

៤) *ការចាប់រំលោភដែលទាក់ទងនឹងការចូលដៃជាមួយជនកំហូចដទៃទៀត* : ការនេះបង្ហាញឲ្យឃើញថា មានការកើនឡើងចំនួនស្ត្រីដែលជាប់ទាក់ទងយ៉ាងសកម្មជួយប្តី ជួយសង្សាររបស់ខ្លួន និងជួយដល់អ្នកដទៃទៀត ក្នុងការប្រើល្បិចបោកក្មេងស្រីៗ ដើម្បីឲ្យគេចាប់រំលោភបានដោយងាយ ប្រហែលបណ្តាលមកពីចង់ជួយការពារបុរសទាំងនោះមិនចង់ឲ្យគេទៅរកស្រីខូច ព្រោះខ្លាចឆ្លងរោគមកខ្លួនដែលជាប្រពន្ធ ឬជាសង្សារ ។

**តើនរណាជាជនល្មើស?**

កុមារគ្រប់អាយុទាំងអស់ និងគ្រប់សាវតារទាំងឡាយអាចក្លាយជាជនរងគ្រោះដោយសារការចាប់រំលោភបាន ជនល្មើសអាចចេញមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ គឺបានសេចក្ដីថា គ្រប់អាយុ គ្រប់មុខរបររកស៊ី និងគ្រប់តួនាទីនៅក្នុងសហគមន៍ ។ ចំពោះករណីជួញដូរកុមារ (ការជួញដូរសំរាប់ធ្វើការងារ ការបំរើផ្លូវភេទ ឬក្នុងគោលបំណងដទៃទៀត) ជនល្មើសតែងតែស្គាល់កុមារជាមុន គឺចេញមកពីរង្វង់គ្រួសារតែម្ដង(ដូចជាឪពុក ពូ អ៊ុំ ឬសូម្បីតែបងប្អូនក៏សឹងតែមាន) ឬជនល្មើសអាចចេញពីសហគមន៍ដែលកុមាររស់នៅជាមួយ ដូចជាអ្នកជិតខាង ឬអ្នកដទៃដែលធ្វើការនៅជិតគ្នា ។ សូម្បីតែក្រុមជំនុំ ទាំងសមាជិក ទាំងអ្នកដឹកនាំ ក៏មិនអាចគេចផុតពីការជួយផ្ដល់ការស្នាក់អាស្រ័យ ការលាក់ខ្លួនដល់អ្នកចាប់រំលោភដ៏មានសក្ដានុពល ឬអ្នកចាប់រំលោភពិតប្រាកដ ហើយថែមទាំងជួយការពារដល់សមាជិករបស់ខ្លួនទៀតផង ។ ករណីភាគច្រើនដែលអង្គការ *លីកាដូ*[៤] បានស៊ើបអង្កេត នោះបានបង្ហាញឲ្យឃើញថា មានជនល្មើសជាកសិករ ឬអ្នកនេសាទ (៣០%) បន្ទាប់មកទៀតជាអ្នកបំរើការក្នុងរដ្ឋាភិបាល (នគរបាល ទាហាន ឬកងរាជអាវុធហត្ថ ១៧%) អ្នកមានមុខរបរផ្សេងៗ ទៀត (ម្ចាស់ផ្ទះជួល អ្នករត់ម៉ូតូឌុប វេជ្ជបណ្ឌិត ជាងមាស ជាដើម ១៤%) ។ ប្រការគួរឲ្យព្រួយបារម្ភនោះគឺ ចំនួនអ្នកចាប់រំលោភភាគច្រើន គឺជាកូនសិស្សសាលា (១៤%) ដែលខ្លះមានអាយុ១៣ឆ្នាំ ។ សារុបសេចក្ដីមក ហេតុការណ៍ទាំងនោះបង្ហាញថា អាយុជាមធ្យមនៃជនល្មើសក្នុងការចាប់រំលោភនោះ គឺអាយុ២៥ឆ្នាំ ការនេះបញ្ជាក់ បង្ហាញឲ្យ

---

*[៤] ដរាបណាករណីទាំងឡាយត្រូវបានគេបង្ហាញឲ្យយើងដឹង ស្ថិតិទាំងអស់បានរៀបចំដកស្រង់ចេញពីករណីទាំងឡាយដែលបានស៊ើបអង្កេតដោយអង្គការលីកាដូ ក្នុងអំឡុងឆ្នាំ ១៩៩៩ និង ២០០០ ។*

ឪពុកម្តាយ គ្រូបង្រៀននៅតាមសាលា និងក្រុមជំនុំត្រូវការផ្តោតនូវការយកចិត្តទុកដាក់យ៉ាងប្រាកដប្រជា និងមិនឯអងទ្បើយក្នុងការបង្រៀនក្មេងប្រុស និងយុវជនទាំងនោះ ចំពោះការដែលគេត្រូវចេះគោរពដល់យុវនារី និងស្ត្រី។

## ច្បាប់ និងការដាក់ទោសដល់ការចាប់រំលោភ

នៅក្នុងប្រទេសកម្ពុជា ការចាប់រំលោភគឺជាបទឧក្រិដ្ឋមួយដែលគួរទទួលទោសតាមច្បាប់ ។ ជនរងគ្រោះបែបនោះ និងគ្រួសាររបស់គេមានសិទ្ធិប្តឹងចោទប្រកាន់ដល់ចំពោះជនល្មើស ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះផង និងដើម្បីជួយការពារស្ត្រី និងកុមារដទៃទៀតមិនឲ្យមានការចាប់រំលោភនៅថ្ងៃអនាគតផង ។ ជនទាំងឡាយណាដែលគេរកឃើញថា មានពិរុទ្ធដោយសារការចាប់រំលោភគេនោះ ត្រូវទទួលទោសដោយជាប់ពន្ធធនាគារ ។ យោងតាមមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌ ចំពោះការដាក់ទោសដល់ដល់ជនល្មើសដែលបានចាប់គេរំលោភនោះមានដូចតទៅ៖

*ការដាក់ទោសជាមធ្យម* : ត្រូវជាប់ពន្ធធនាគារ ពី៥-១០ ឆ្នាំ

*ការចាប់រំលោភដោយមានការបន្លំ ការប្រើអំពើហិង្សា ឬការគំរាមកំហែង* : ត្រូវជាប់ពន្ធធនាគារពី ១០-១៥ ឆ្នាំ ។

*ការចាប់រំលោភដោយបុគ្គលដែលមានអំណាចគ្រប់គ្រងលើជនរងគ្រោះ (ដូចជា នគរបាល ចៅហ្វាយនាយនៅកន្លែងធ្វើការងារជាដើម)* : ត្រូវជាប់ពន្ធធនាគារពី ១០-១៥ ឆ្នាំ ។

*ការចាប់រំលោភដល់មនុស្សដែលមិនទាន់គ្រប់អាយុ (មនុស្សដែលមានអាយុក្រោម ១៦ឆ្នាំ)* : ត្រូវជាប់ពន្ធធនាគារទ្វេដងនៃចំនួនឆ្នាំ ដែលបានពោលខាងលើ ។

## ចូរប្រុងប្រយត្ន័

ពីព្រោះរឿងនេះគឺគ្រាន់តែជាការពិភាក្សាដ៏តូចតាច និងការដែលត្រូវយល់ដឹង នៅមានរឿងរ៉ាវជាច្រើនទៀត ដែលមានការយល់ច្រឡំចំពោះមូលហេតុនូវការចាប់រំលោភ និងឥទ្ធិពលនូវការចាប់រំលោភនោះប៉ះពាល់ធ្ងន់ធ្ងរចំពោះជនរងគ្រោះ ។ ហេតុដូច្នេះហើយមានមនុស្សជាច្រើន (សូម្បីតែឪពុកម្តាយ) ជាញឹកញាយតែងតែចោទប្រកាន់ដល់ជនរងគ្រោះថា មានធ្វើអ្វីមួយដែលបណ្តាយ ឬអនុញ្ញាតឲ្យមានករណីចាប់រំលោភនេះកើតឡើង ។ ដោយហេតុនោះគេមិនបានដឹងពីអារម្មណ៍ និងសេចក្តីត្រូវការរបស់ជនរងគ្រោះ ហើយគេបែរទៅជាមិនជួយគាំទ្រ និងផ្តល់នូវសេចក្តីត្រូវការដែលជនរងគ្រោះត្រូវការដើម្បីជួសជុលផ្លូវចិត្តគេឡើងវិញ ។ ក្នុងនាមជាឪពុកម្តាយ គ្រូស្តបរិស័ទ ជាសាច់ញាតិ ឬជាក្រុមជំនុំ និងសមាជិករស់នៅក្នុងសហគមន៍ជាមួយគ្នា យើងជាមនុស្សទាំងអស់គ្នាត្រូវតែយល់ និងមានចិត្តមេត្តាករុណាចំពោះជនរងគ្រោះ និងត្រូវដឹងនូវរបៀបដ៏សមរម្យផ្តល់នូវការគាំទ្រដល់គេ ។ ការនេះចាប់ផ្តើមឡើងជាមួយការយល់ដឹងនូវជំនឿមិនត្រឹមត្រូវខ្លះដែលមនុស្សទាំងឡាយមាន ចំពោះករណីនៃការចាប់រំលោភ ហើយនិងឥទ្ធិពលរបស់ជំនឿនោះដែលមានផលប៉ះពាល់ដល់ស្រ្តី និងកុមារ ។

### ទស្សនៈខុសឆ្គងបួនយ៉ាងដែលទាក់ទងទៅនឹងការចាប់រំលោភ

ទស្សនៈទី១: ស្រ្តីដែលទាក់ទាញឲ្យមានការចាប់រំលោភ ដោយការស្លៀកសម្លៀកបំពាក់លេចមុខលេចក្រោយមានអាការៈបង្ហាញឲ្យប្រុសស្រើបស្រាល ការដើរតែឯងនៅពេលយប់ស្ងាត់ជាដើម ។

*ការពិត : គ្មានសម្លៀកបំពាក់ ឬអាការៈណាមួយ ដែលផ្តល់សិទ្ធិឲ្យបុរសទៅចាប់ស្រ្តី ឬកុមាររំលោភនោះឡើយ ។*

ការនិយាយរឿងនេះ គឺជាការមួយខុសឆ្គង ដោយគេកំពុងបង្វែរការស្តីបន្ទោសពីជនល្មើស ទៅបន្ទោសលើជនរងគ្រោះទៅវិញ ហើយបែរទៅជាមិនបានអើពើ ចំពោះហេតុការណ៍ដែលថា កុមារវ័យក្មេងដែលត្រូវគេរំលោភនោះមិនទាន់ដឹងអ្វីថាការស្លៀកពាក់បែបនេះ ឬមានអាក្សកិរិយាបែបនោះបណ្តាយឲ្យមានការចាប់រំលោភនោះឡើយ ។

ទស្សនៈទី២: បុរសមិនអាចការពារឃុំគ្រងនូវបំណងប្រាថ្នាក្នុងការសេពសន្ធវៈរបស់ខ្លួនបានទេ ការចាប់រំលោភ គឺវាកើតឡើងឯងៗតែម្តង ។
*សេចក្តីពិត: តាមការសិក្សាស្រាវជ្រាវនៅសហរដ្ឋអាមេរិក និងនៅប្រទេសអង់គ្លេសបានបង្ហាញថា ការចាប់រំលោភភាគច្រើន គឺសុទ្ធតែរៀបគម្រោងទាំងស្រុង ឬរៀបចំផែនការផ្នែកខ្លះៗ មានតែ ១៥% ប៉ុណ្ណោះដែលកើតឡើងលក្ខណៈតម្រេកពុះកញ្ជ្រោលមិនដឹងខ្លួន ។*
តែមានមនុស្សជាច្រើនជឿថា អ្នកចាប់រំលោភទាំងឡាយ គឺជាមនុស្សមានតណ្ហាស្រេកឃ្លានហួសហេតុ យោងតាមការសិក្សាស្រាវជ្រាវទាំងនេះក៏បានបង្ហាញផងដែរថា ជនល្មើសភាគច្រើនអាចជាមនុស្សរៀបការរួច ឬជាមនុស្សធ្លាប់មានទំនាក់ទំនងជាមួយសង្សាររបស់ខ្លួន ធ្លាប់ជាមួយនឹងស្រីពេស្យាជាដើម ។

ទស្សនៈទី៣: អ្នកចាប់រំលោភភាគច្រើនគឺសុទ្ធសឹងតែជាមនុស្សមិនធ្លាប់ស្គាល់ជនរងគ្រោះ ។
*សេចក្តីពិត : ការចាប់រំលោភភាគច្រើន គឺធ្វើឡើងដោយមនុស្សដែលបានស្គាល់ជនរងគ្រោះ ។*
ចំពោះករណីទាំងអស់ដែលអង្គការ *លីកាដូ* បានស៊ើបអង្កេតឃើញនោះមាន ៦៨% នៃជនល្មើស គឺជាមនុស្សដែលស្គាល់ជនរងគ្រោះយ៉ាងច្បាស់ (សាច់ញាតិ ឬអ្នកដទៃដែលរស់នៅក្នុងផ្ទះជាមួយគ្នា ជាសង្សារ ជាអ្នកជិត

ខាង និងជាមិត្តសម្លាញ់) ចំណែកឯអ្នកចាប់រំលោភដែលមិនសូវស្គាល់ជនរងគ្រោះ ឬមិនសូវជិតដិតនឹងជនរងគ្រោះនោះ មានតែ ២៥% តែប៉ុណ្ណោះ ។

ទស្សនៈទី៤: ស្ត្រីភាគច្រើនចោទប្រកាន់បុរសដោយមិនត្រឹមត្រូវថាគេចាប់រំលោភខ្លួន ។

*សេចក្តីពិត : ការចាប់រំលោភ គឺជាបទឧក្រិដ្ឋមួយបែបក្នុងចំណោមបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត ដែលគេមិនសូវរាយការណ៍ឡើយ ។*

តាមការសិក្សាស្រាវជ្រាវនៅសហរដ្ឋអាមេរិកបង្ហាញឲ្យដឹងថា មានតែ២% នៃការរាយការណ៍ពីករណីចាប់រំលោភដែលបង្ហាញថាការអះអាងនោះមិនពិត ។ នៅក្នុងប្រទេសកម្ពុជា វាជារឿងមួយមិនទំនងឡើយដែលថាស្ត្រី ឬកុមារធ្វើការចោទប្រកាន់មិនត្រឹមត្រូវពីករណីចាប់រំលោភនោះ ព្រោះមានហេតុផលបីយ៉ាងគឺ៖ ទី១) មានការអៀនខ្មាសចំពោះការដែលទាក់ទងទៅនឹងការចាប់រំលោភ និងសកម្មភាពទាក់ទងនឹងផ្លែកភេទនេះ នៅក្នុងទំនៀមទំលាប់ខ្មែរ គ្រួសារ និងសាច់ញាតិបងប្អូនមានការអៀនខ្មាសក្នុងការទទួលយកការនោះណាស់ ហើយម្យ៉ាងទៀតធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ស្ត្រីនោះ និងធ្វើឲ្យប៉ះពាល់ដល់ឱកាសនៃការរៀបការរបស់នាងទៀតផង ។ ទី២) ការប្រព្រឹត្តិរបស់អាជ្ញាធរចំពោះករណីចាប់រំលោភនេះ មិនសូវចេះយោគយល់ទើបឲ្យមានការលំបាកក្នុងការចងក្រងពាក្យបណ្តឹង ហើយនិង ទី៣) ការភ័យខ្លាច និងការមិនទុកចិត្តដល់ប្រពន្ធ័ច្បាប់ បណ្តាលឲ្យស្ត្រីភាគច្រើនមិនជឿថា គេអាចទទួលបាន

នូវភាពយុត្តិធម៌ ។ ដោយសារតែការលំបាកទាំងនេះហើយដែលស្ត្រីខ្មែរ ឬកុមារខ្មែរមិនទំនងជាកុហកចំពោះបញ្ហាការចាប់រំលោភនេះឡើយ ។[៥]

ដោយសារតែទស្សនៈទាំងអស់ខាងលើនេះហើយ ទើបការចោទប្រកាន់លើករណីចាប់រំលោភតែងតែមិនសូវបានគេយកចិត្តទុកដាក់ប្រាកដប្រជានៅក្នុងគ្រួសារ ឬក្នុងសហគមន៍ឡើយ ។ តែទោះជាយ៉ាងក៏ដោយ *គឺថាការចាប់រំលោភនេះជាបទឧក្រិដ្ឋដែលមិនអាចដោះសាបាន និងជាអំពើបាបដ៏គួរឲ្យសោកស្ដាយដែលនាំមកនូវសេចក្ដីទុក្ខសោកទាស់នឹងព្រះជាម្ចាស់ ។*

## ឥទ្ធិពលនៃការចាប់រំលោភដែលប៉ះពាល់ដល់ជនរងគ្រោះ

នេះគឺជារឿងពិតរបស់នាង "ថានី" (ឈ្មោះទាំងអស់នៅក្នុងករណីសំរាប់សិក្សានេះសុទ្ធតែត្រូវបានផ្លាស់ប្ដូរទាំងអស់ហើយ) គឺ៖

*នៅក្នុងឆ្នាំ ១៩៩៩ កុមារីអាយុ៧ឆ្នាំម្នាក់ ឈ្មោះ ថានី ត្រូវបានមិត្តភក្តិរបស់នាងឈ្មោះ ដារា បបួលឲ្យទៅលេងនៅផ្ទះអ្នកជិតខាងរបស់នាង ។ នាងមានចិត្តស្ទាក់ស្ទើរមិនចង់ទៅទេ ហើយក្រោយមកបាននិយាយថា បងប្រុសរបស់ ដារា អាយុ១៣ ឆ្នាំ បានចាប់រំលោភនាងថានី យ៉ាងហោចណាស់បីដងកាលពីពេលមុនៗ ។ ដោយសារម្ដាយចេះតែជំរុញឲ្យទៅ ថានី ក៏ព្រមទៅលេងជាមួយ ដារា ។ បន្ទាប់ពីរត់លេងមួយស្របក់ក្រោយមក ដារា ក៏បបួលទៅងូតទឹកលេងនៅឯស្រះទឹក ហើយនៅពេលដែលគេនាំគ្នាងូតទឹករួចហើយ ថានី ក៏ប្រញាប់ប្រញាល់វិលត្រឡប់មកផ្ទះ ប៉ុន្តែ ដារា បានហៅបងប្រុសរបស់ខ្លួនដោយប្រាប់ថា ថានីកំពុងត្រឡប់ទៅវិញហើយ ។*

---

*[៥] ហេតុដូច្នេះហើយ បានជាស្ថិតិបង្ហាញថា ស្ត្រីខ្មែរមិនទំនងជានិយាយកុហក ដើម្បីចោទប្រកាន់ចំពោះបុរសនោះទេ ទោះបីការនេះវាអាចកើតឡើងក៏ពិតមែន ។ នៅទីនេះ ក៏ដូចនៅកន្លែងដទៃដែរ ជនចាប់ចោទតែងតែអះអាងថាខ្លួនគ្មានកំហុសអ្វីឡើយ រហូតដល់រកបានភស្តុតាងគ្រប់គ្រាន់ ទើបព្រមសារភាពនិងព្រមឡើងទៅតុលាការ ។*

បងប្រុសរូបនោះបានចេញមក ហើយចាប់ ថានី ដោយយកដៃបិទមាត់របស់នាង ហើយក៏អូសនាងទៅក្បែរគល់ត្នោតជិតនោះ ។ បន្ទាប់មកវាបានស្រែកប្រាប់ ដារា ឲ្យទៅរកកន្ទេលមួយ និងក្រមាបី(០៣)មកឲ្យវា ។ បន្ទាប់មកក្មេងប្រុសនោះបានប្រកួកហៅមិត្តភក្តិរបស់ខ្លួនពីរនាក់ទៀត ដែលមានអាយុ ១២ ឆ្នាំម្នាក់ និង១៣ ឆ្នាំម្នាក់ ។ នៅពេលដែល ដារា ក្រាលកន្ទេលរួចហើយក្មេងប្រុសទាំងបីបង្ខំ ថានី ឲ្យដេកនៅលើកន្ទេល ហើយពួកវាបានយកក្រមាចងបិទមាត់ ក្រោយមកទៀតចងដៃភ្ជាប់ទៅនឹងដើមឈើដែលនៅក្បែរនោះ។ ពួកវាបានចងជើងរបស់នាងឲ្យកន្ធែកពីគ្នា ហើយបន្ទាប់មកពួកវាចាប់ផ្តើមដំណើរការចាប់រំលោភម្តងម្នាក់ៗ គឺម្នាក់ៗបានសម្រេចពីរដងគ្រប់គ្នា ។ នៅពេលដែលក្មេងប្រុសទាំងនោះកំពុងចាប់រំលោភ ដារា កំពុងអង្គុយយាមផ្លូវមិនឆ្ងាយពីទីនោះប៉ុន្មានទេ ។

បន្ទាប់មកក្មេងប្រុសទាំងនោះបាននាំ ថានី ទៅឯស្រះទឹក ហើយចងម្តងទៀត ហើយរំលោភនាងម្នាក់ៗពីរដងទៀត ។ នាង ថានី បានទទួលរងនូវការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសាររឿងនោះ និងមានបញ្ហាផ្នែកសតិអារម្មណ៍តាំងពីពេលនោះមក ។ នាងក៏មានរបួសធ្ងន់ធ្ងរ នៅត្រង់ប្រដាប់ភេទរបស់នាងផងដែរ ដែលត្រូវការការព្យាបាលពីសំណាក់គ្រូពេទ្យ ។ ពួកអ្នកស៊ើបអង្កេតរបស់អង្គការ លីកាដូ បានធ្វើអន្តរាគមន៍ ដើម្បីឲ្យនគរបាលចាប់ក្មេងប្រុសទាំងនោះដែរ ដែលមកទល់ពេលនេះ ក្មេងប្រុសនោះនៅតែរស់នៅយ៉ាងសុខសាន្តនៅក្នុងភូមិជិតនឹងជនរងគ្រោះ ។ នៅក្នុងពេលធ្វើការស៊ើបអង្កេតនោះ គេបានដឹងថាក្មេងប្រុសទាំងបីនាក់នោះបានមើលកុនរឿងកូនជ្រូក (រឿងអាសអាភាស) នៅកន្លែងបញ្ចាំងជិតនោះ ហើយការនោះបញ្ជាក់ឲ្យឃើញថា ក្មេងទាំងនោះរៀនតាមរូបអាសអាភាសនៅក្នុងវីដេអូ ដែលពួកគេបានមើលនោះយកមកធ្វើតាម ។

សូមគិតពិចារណាមួយស្របក់មើល តើលោកអ្នកមានអារម្មណ៍បែបណាដែរ បើសិនលោកអ្នកជា ថានីវិញនោះ គឺថា៖ ទី ១) នៅអំឡុងពេលចាប់រំលោភ ទី២ បន្ទាប់ពីការចាប់រំលោភ ហើយនិង ទី៣) នៅពេលដែលនាងប្រាប់ដល់សមាជិកគ្រួសារ ប្រាប់ដល់នគរបាល និង ប្រាប់ដល់តុលាការស្ដីពីបទពិសោធន៍នោះ ។ តើលោកអ្នកគិតយ៉ាងណា ចំពោះខ្លួនលោកអ្នកផ្ទាល់ គិតពីជនល្មើស គិតពីមិត្តសម្លាញ់ដែលបានក្បត់លោកអ្នក និងបង្ខូចអនាគតរបស់លោកអ្នកនោះ?

ប្រហែលដោយសារតែទស្សនៈខុសឆ្គងដែលបានពណ៌នាខាងលើ និងដោយសារតែលក្ខណៈនៃបទឧក្រិដ្ឋនេះធ្ងន់ធ្ងរ ទើបមានមនុស្សជាច្រើនមិនបានសញ្ជឹងគិតឲ្យបានជ្រាលជ្រៅអំពីអារម្មណ៍របស់ជនរងគ្រោះដោយសារគេចាប់រំលោភនោះថាមានអារម្មណ៍យ៉ាងណាឡើយ ។ ដោយហេតុនោះ ទើបមានការខ្វះខាតយ៉ាងធ្ងន់ធ្ងរចំពោះការយល់ដឹងអំពីផលប៉ះពាល់ផ្នែកផ្លូវចិត្ដដល់ជីវិតរស់នៅរបស់ជនរងគ្រោះដោយគេចាប់រំលោភនោះ ។ គ្រប់ផ្នែកទាំងអស់នៅក្នុងសង្គមត្រូវតែទទួលនូវការអប់រំឲ្យបានដឹងពីឥទ្ធិពលនៃការចាប់រំលោភដែលប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវចិត្ត របស់ស្ត្រី និងកុមារ តួយ៉ាងដូចជានាងថានីនេះ ។ ការទាំងអស់នេះអាចគិតបញ្ចូលទាំងការងារដូចតទៅនេះ គឺ៖

១. **ការប៉ះពាល់ផ្នែករាងកាយ**

- ការរងរបួសផ្នែកផ្លូវកាយ ដោយសារការបង្ខំរបស់ជនល្មើស។
- ប្រហែលជាអាចឆ្លងមេរោគ HIV/AIDS
- ជម្ងឺកាមរោគដទៃទៀត (ប្រមះ ស្វាយក្រាប សិរមាន់ មានដំបៅក្លាយនៅតាមបំពង់បង្ហូរទឹកមូត្រ និងមានជម្ងឺដុះសាច់នៅលើប្រដាប់ភេទ)

- ការមានផ្ទៃពោះដែលមិនចង់បាន ឬការមានផ្ទៃពោះចំពោះស្ត្រីវ័យក្មេងពេក ។
- ការក្អួតចង្អោរ អស់កម្លាំង ឈឺក្បាលខ្លាំង ឈឺពោះ និងរបួសត្រង់ប្រដាប់ភេទ ។

២. **ការប៉ះពាល់ផ្នែកផ្លូវចិត្ត**

- មានការថប់បារម្ភធ្ងន់ធ្ងរ ភ័យខ្លាច ធ្លាក់ទឹកចិត្ត ជាប់ពិរុទ្ធក្នុងចិត្ត បន្ទោសខ្លួនឯង ឯកោ ត្រមង់ត្រមោច ខឹង មានអាការៈច្រងេងច្រងាង ។
- មានភាពអាម៉ាស់ ខ្មាសគេ ខ្វះទំនុកចិត្តខ្លួនឯង មើលមកខ្លួនឯងថាឥតប្រយោជន៍ ។
- មិនសូវឃ្លានអាហារ មានបញ្ហាដេកនោមយប់រាំរ៉ៃ ។
- ខូចចិត្តយ៉ាងខ្លាំង ។
- ចង់ធ្វើអត្តឃាត ។

*នៅក្នុងឆ្នាំ ២០០២ ចិន្ដា អាយុ៨ឆ្នាំ ត្រូវអ្នកជិតខាងរបស់នាងចាប់រំលោភបានពីរដង ហើយអ្នកជិតខាងនោះបានប្រាប់នាងថា កុំឲ្យប្រាប់នរណាឲ្យសោះ បើពុំនោះទេគាត់នោះនឹងសម្លាប់នាងចោល ។ នៅថ្ងៃមួយម្ដាយរបស់នាងងូតទឹកឲ្យនាង ម្ដាយនាងសង្កេតឃើញថា មានអ្វីមួយដែលខុសធម្មតាក៏ឈ្លេចសួរកូនស្រីរបស់គាត់ ។ នៅពេលដែល ចិន្ដា បដិសេធមិនព្រមប្រាប់ទាំងឪពុកទាំងម្ដាយរបស់នាងយកខ្សែភ្លើងមកវាយធ្វើបាបនាង ។ បន្ទាប់មកនាងក៏ព្រមសារភាពថានាងត្រូវគេចាប់រំលោភ ហើយពេលនោះនាងភ័យញ័រយ៉ាងខ្លាំងដោយព្រោះខ្លាចបុរសម្នាក់នោះមករកនាងឃើញ រួចធ្វើបាបនាងទៀត ។ គ្រួសាររបស់នាងបាននិយាយថា ឥឡូវនេះនាងភ័យខ្លាចយ៉ាងខ្លាំងចំពោះមនុស្សដទៃទៀតដែលដើរមកជិតនាង ហើយបានប្រាប់ទៀតថា គេចង់*

ឲ្យនាងទទួលបាននូវការប្រឹក្សា ផ្តល់យោបល់ ដើម្បីឲ្យបានរួចផុតពីសេចក្តីភ័យខ្លាចនេះ ។

នៅក្នុងឆ្នាំ ២០០១ ក្មេងស្រីម្នាក់ អាយុ៧ឆ្នាំ ឈ្មោះ សុផល ត្រូវគេចាប់រំលោភ៤ ទៅ៥ដង ត្រូវគេវាយដំ ហើយចាក់សោទុកនៅក្នុងកន្លែងសម្ងាត់មួយអស់រយៈពេលជាច្រើនថ្ងៃ ។ នៅពេលដែលគេទៅរកនាងឃើញ គឺនាងសន្លប់បាត់ស្មារតីទៅហើយ ព្រោះនាងបាត់បង់ឈាមច្រើនពេក ហើយនាងត្រូវការទទួលការថែទាំនៅមន្ទីរពេទ្យជាបន្ទាន់ ។ នៅពេលបច្ចុប្បន្ននេះនាងដេកយល់សប្តិអាក្រក់រៀងរាល់យប់ និងដេកនោមដាក់គ្រែរាល់យប់ នាងមានការភ័យខ្លាចចំពោះមនុស្សចម្លែក (ជាពិសេសមនុស្សប្រុស) មិនហ៊ានដើរទៅណាឡើយបើគ្មានម្តាយនាងទៅជាមួយ ហេតុដូច្នេះទើបនាងមិនអាចទៅរៀននៅឯសាលាបាន ។ នៅពេលដែលលេងជាមួយបងប្អូនរបស់នាង ស្រាប់តែមានបញ្ចេញអាការៈឃោរឃៅភ្លាម និងខឹងតូងតែម្តង ។ ពួកអ្នកផ្តល់ការប្រឹក្សាឲ្យយោបល់ដែលបានមកជួប សុផល បានសង្កេតឃើញថា នាងមិនបានទទួលនូវការបើកឱកាសនិយាយ និងបង្ហាញពីអារម្មណ៍របស់នាងដែលត្រូវគេចាប់រំលោភនោះ ទើបនាងត្រូវបញ្ចេញតាមផ្លូវផ្សេង ឧទាហរណ៍នៅពេលដែលនាងកំពុងលេងជាមួយបងប្អូន ។

នៅក្នុងឆ្នាំ ២០០០ ក្មេងស្រីម្នាក់អាយុ១៥ឆ្នាំ ឈ្មោះ សុភា ត្រូវពួកជើងកាងអាយុ១៨ឆ្នាំដែលនៅក្នុងភូមិជាមួយនាងដែរ ចាប់នាងរំលោភ ។ នាងត្រូវជនល្មើសវាយដំយ៉ាងខ្លាំង នៅក្នុងពេលដែលគេចាប់នាងរំលោភនោះ រាងកាយត្រូវជាំសព្វសាច់ និងមានរបួសនៅក្នុងប្រដាប់ភេទរបស់នាង ។ បន្ទាប់ពីទទួលរងនូវការឈឺចាប់នេះរួចមក សុភា ទទួលរងនូវការឈឺចាប់មួយបែបទៀត គឺការដេកយល់សប្តិអាក្រក់នៅពេលយប់ មានការភ័យខ្លាចយ៉ាងខ្លាំងនៅពេលដែលនាងនៅតែឯង និងយំភ្លាមមួយរំពេច ។

ការប៉ះពាល់រយៈពេលយូរនៃការចាប់រំលោភ អាចគិតបញ្ចូលទាំងការផ្លាស់ប្ដូរបុគ្គលិកលក្ខណៈ ខ្វះការទុកចិត្តដល់អ្នកដទៃ មានទុទិដ្ឋិនិយមចំពោះថ្ងៃអនាគត បាត់បង់ការទុកចិត្តលើខ្លួនឯង ហើយនិងមិនទុកចិត្តចំពោះមនុស្សពេញវ័យទាំងអស់ ។ ទំនាក់ទំនងនៅក្នុងសហគមន៍ក៏មានការប៉ះពាល់ដែរ ក្នុងនាមជាក្មេងស្រីដែលបាត់បង់ភាពបរិសុទ្ធរបស់ខ្លួននោះ នៅក្នុងទំនៀមទំលាប់ខ្មែរទទួលរងនូវការខូចកេរ្តិ៍ឈ្មោះយ៉ាងខ្លាំងចំពោះការនោះ បានធ្វើឲ្យនាងបែងចែកវណ្ណៈ ពីសំណាក់មិត្តភក្តិ និងអ្នកជិតខាង ហើយថែមទាំងបន្ថយនូវឱកាសដែលអាចរៀបការនោះកាន់តែធ្ងន់ធ្ងរថែមទៀតផង ។ ការសិក្សាស្រាវជ្រាវក៏បង្ហាញផងដែរថា ជនរងគ្រោះដែលត្រូវគេចាប់រំលោភនោះមានការងាយរងគ្រោះថ្នាក់ខ្លាំងណាស់ក្នុងការចាប់រំលោភម្ដងទៀត ឬត្រូវទទួលរងនូវការដែលគេយកទៅលក់ ឬត្រូវគេបង្ខំឲ្យធ្វើជាស្រីពេស្យាច្រើនជាងស្រីដទៃនៅក្នុងសហគមន៍ ។

ការទាំងនេះបង្ហាញយ៉ាងច្បាស់ពីការកែកុនជីវិតរស់នៅដែលមានការប៉ះពាល់លើជនរងគ្រោះនោះ ហើយថែមទាំងមានផលប៉ះពាល់ដល់គ្រួសាររបស់ជនរងគ្រោះផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ គឺផលប៉ះពាល់ខាងលើនេះមិនទាន់បង្ហាញឲ្យឃើញភ្លាមនោះទេ តែមិនមែនបានសេចក្ដីថា បញ្ហានោះមិនបានកើតឡើង ឬបានន័យថា ជនរងគ្រោះបានជានាឡើងដូចគេដូចឯងដែរនោះឡើយ ។ នាងប្រហែលជាអាចខំបំភ្លេច ឬខំលាក់ពីអារម្មណ៍ភ័យខ្លាចរបស់នាងមិនឲ្យនរណាយល់បាន ។ ទោះករណីណាក៏ដោយ គឺជាការសំខាន់ណាស់ក្នុងនាមយើងជាសមាជិកគ្រួសារ អ្នករស់នៅក្នុងសហគមន៍ និងក្នុងនាមជាសមាជិកក្រុមជំនុំ ត្រូវដឹងពីអារម្មណ៍របស់ជនរងគ្រោះដូចជានាង ថានី ហើយត្រូវបង្ហាញពីសេចក្ដីស្រឡាញ់ដ៏ឥតលក្ខខ័ណ្ឌរបស់គ្រីស្ដបរិស័ទ ត្រូវព្រមទទួលរាប់អាន និងផ្ដល់ការគាំទ្រដល់នាង ។

## ត្រូវប្រុងជើងការចំពោះរឿងនេះ

"ការប្រុងជើងការ" មានន័យថា លោកអ្នកត្រូវធ្វើអ្វីមួយ ដើម្បីការពារបញ្ហានោះមុនពេលវាកើតឡើង ឬបើសិនជាវាកើតឡើងរួចហើយនោះ ត្រូវយកការទទួលខុសត្រូវផ្ទាល់ខ្លួនមកដោះស្រាយបញ្ហានោះឲ្យបានប្រសើរបំផុតតាមលទ្ធភាពរបស់ខ្លួន ។ ចំពោះបញ្ហាដែលប៉ះពាល់នឹងដួងចិត្ត និងធ្វើឲ្យខ្វល់ខ្វាយដូចជាករណីចាប់រំលោភនោះ គឺវាងាយធ្វើឲ្យយើងបដិសេធ ឬមិនអើពើចំពោះបញ្ហានោះជាជាងការដែលយើងត្រូវទៅប្រឈមមុខ និងត្រូវមានការចូលរួមក្នុងការគាំពារដល់កុមាររងគ្រោះ ។ ប៉ុន្តែក្នុងនាមយើងជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់បានត្រាស់ហៅយើងមក ឲ្យយើងយកព្រះបន្ទូលរបស់ព្រះអង្គទៅជួយដោះស្រាយបញ្ហាលោកិយ៍ យើងត្រូវតែមានស្មារតីប្រុងជើងការ(ត្រៀមខ្លួនជាស្រេច) និងផ្តល់នូវសេចក្តីត្រូវការដ៏គ្រប់ជ្រុងជ្រោយដល់កុមារ និងមនុស្សពេញវ័យទាំងឡាយដែលត្រូវការយើង ។ សូមព្រះអង្គប្រទានពរនូវគតិបណ្ឌិត អំណោយទានផ្សេងៗរបស់ព្រះវិញ្ញាណ លើសពីនោះទៅទៀតនោះ គឺជាអំណោយទាននៃសេចក្តីស្រឡាញ់ គឺព្រះជាម្ចាស់បានប្រដាប់កាយយើងឲ្យមានគ្រប់យ៉ាង ដើម្បីឲ្យយើងអាចឆ្លើយតបចំពោះបញ្ហាការចាប់រំលោភកុមារនេះ ។ យើងទាំងអស់គ្នា ក្នុងតួនាទីជា ឪពុកម្តាយជាសាច់ញាតិ ជាក្រុមជំនុំ ឬជាសមាជិករស់នៅក្នុងសហាមគមន៍ ជាមួយគ្នាយើងអាចផ្តល់នូវស្មារតីប្រុងជើងការតាមមធ្យោបាយដូចខាង ក្រោមនេះគឺ៖

### ឪពុកម្តាយ និងសមាជិកក្នុងគ្រួសារ

- ចូរពិភាក្សាជាមួយកូនរបស់លោកអ្នក តាមរបៀបមួយដែលសមរម្យនឹងអាយុ ហើយនិងស៊ីនឹងការយល់ដឹងរបស់គេ ស្តីពីបញ្ហាដែលទាក់ទងទៅនឹងការចាប់រំលោភ ។ ចូរប្រាប់ឲ្យគេបានដឹងថា គឺជាការ

មិនត្រឹមត្រូវឡើយ បើមានមនុស្សណាម្នាក់មកប៉ះពាល់ ឬធ្វើការឃាឃីដល់ផ្នែកភេទ ត្រូវឲ្យគេចេះប្រយ័ត្នខ្លួននៅពេលចេញដើរទៅណាមកណាតែម្នាក់ឯងនៅក្នុងកន្លែងដែលស្ងាត់នោះ ហើយត្រូវរត់រកឲ្យគេជួយ បើសិនជាគេមានការភ័យខ្លាចថា មានគេបំរុងនឹងធ្វើបាបតាមរបៀបណាមួយនោះ ។

- ចូរប្រាប់ដល់កូនថាគេមានសេរីភាពគ្រប់គ្រាន់ ក្នុងការនិយាយប្រាប់ពីបញ្ហារបស់គេប្រាប់មកលោកអ្នកគ្រប់ពេលវេលា និងប្រាប់កូនឲ្យដឹងថាសូម្បីតែកូននោះត្រូវគេចាប់រំលោភក៏ដោយ លោកអ្នកនៅតែអះអាងឲ្យគេដឹងថាលោកអ្នកនៅតែស្រឡាញ់គេដដែល ព្រមស្តាប់ និងផ្តល់ការគាំទ្រដល់គេដោយឥតមានលក្ខខ័ណ្ឌឡើយ ។
- ចូររៀនសំគាល់ និងសង្កេតមើលពីសញ្ញាទាំងឡាយដែលទាក់ទងនឹងផ្នែករាងកាយ ឬផ្នែកផ្លូវចិត្តកូនរបស់លោកដែលអ្នកត្រូវគេចាប់រំលោភ (ដូចមានចែងក្នុងបញ្ជីខាងលើ) ហើយបើសិនលោកអ្នកមានការសង្ស័យថា មានគេចាប់រំលោភ ចូរលួងលោមកូន ដោយផ្តល់ឱកាសឲ្យកូនអាចនិយាយប្រាប់លោកអ្នកពីការទាំងនោះ ។ ចូរកុំបង្ខំកូន ព្រោះការនោះអាចបន្ថែមនូវការប៉ះពាល់ផ្នែកផ្លូវចិត្តកាន់តែធ្ងន់ធ្ងរថែមទៀត ។ កូននោះគង់តែនឹងប្រាប់លោកអ្នក ឬមនុស្សណាម្នាក់ដែលគេទុកចិត្ត បើសិនយើងផ្តល់ឱកាសគ្រប់គ្រាន់ឲ្យដល់គេ ។
- ចូរពិចារណាមើលឲ្យមានល្អិតល្អន់ បន្ទាប់ពីពិភាក្សាជាមួយកូនរបស់លោកអ្នករួចហើយនោះ ចូររាយការណ៍ការនេះទៅនគរបាល ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រុមអង្គការសិទ្ធិមនុស្ស ដូចជាអង្គការ *លីកាដូ* ឬអង្គការក្រៅរដ្ឋាភិបាលដទៃទៀត ដូចជា មជ្ឈ

មណ្ឌលស្តារនីតិសម្បទាស្ត្រីកម្ពុជា[៦] ។ ចូរធ្វើពាក្យបណ្តឹងជូនទៅកន្លែងទាំងអស់នេះ ដើម្បីអាចឈានទៅរកការចាប់ខ្លួនជនល្មើស និងជួយការពារកុមារដទៃទៀតឲ្យរួចពីការរងឈឺចាប់ដោយការចាប់រំលោភនេះនៅថ្ងៃក្រោយទៀត ។

ក្រុមជំនុំ

- ចូរប្រកាសប្រាប់ដល់សមាជិកក្រុមជំនុំដទៃទៀតពីបញ្ហានោះ តាមរបៀបមួយដ៏សមរម្យ តាមពេលវេលា និងកន្លែងដែលសមរម្យ ប្រាប់ពីរឿងដែលគេនិយាយតៗគ្នា ប្រាប់ពីរឿងរ៉ាវពិតប្រាកដ និងឥទ្ធិពលដែលប៉ះពាល់ចំពោះការចាប់រំលោភនេះដល់ស្ត្រី និងកុមារ។ ឧទាហរណ៍ ដូចជាការនាំគ្នាអានផ្នែកខ្លះៗនៃអត្ថបទនេះ នៅក្នុងក្រុមតូចរបស់ស្ត្រី ហើយបន្ទាប់មកពិភាក្សាគ្នា នេះគឺជាមធ្យោបាយមួយដែលយើងអាចធ្វើបានចំពោះការនេះ ។
- បង្ហាញពីសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ និងផ្តល់នូវការគាំទ្រគ្រប់យ៉ាងទាំងអស់ដល់ជនរងគ្រោះដែលត្រូវគេចាប់រំលោភ។ ចូរធ្វើការនេះដោយគ្មានការនិយាយខ្សិបខ្សៀវពីរឿងរ៉ាវអាស្រូវរបស់គេ ឬនិយាយអ្វីដែលធ្វើឲ្យគេមានការអាម៉ាស់ឡើយ គ្រាន់តែបង្ហាញពី

---

*[៦]ប៉ុស្តិ៍នគរបាលជាតិៈ ០២៣ ៧២០៥៥៥; អង្គការទេសន្រ្ទះពិភពលោកមជ្ឈមណ្ឌលនាវាថ្មីៈ ០២៣ ៨៨០៣៤២; មជ្ឈមណ្ឌលស្តារនីតិសម្បទាស្ត្រីកម្ពុជាៈ ០២៣ ៩៨២១៥៨ ឬ ០១២ ៨៤០៥០៧; អង្គការលីកាដូៈ ភ្នំពេញៈ ០២៣ ៣៦០៩៦៥/ ២១៧៦២៦; បន្ទាយមានជ័យៈ ០៥៤ ៩៥៨៨៦១; បាត់ដំបងៈ ០៥៣ ៩៥២៨២៨; កោះកុងៈ ០៣៥ ៩៣៦១១៦; កំពង់ចាមៈ ០៤២ ៩៤១៤៦៤; កំពង់ឆ្នាំងៈ ០២៦ ៩៨៨៦៣៧; កំពង់ស្ពឺៈ ០២៥ ៩៨៧២២០; កំពង់ធំៈ ០៦២ ៩៦១២៩២; កំពតៈ ០៣៣ ៩៣២៦៦៣; ព្រៃវែងៈ ០៤៣ ៩៤៤៥២៧; ពោធិ៍សាត់ៈ ០៥២ ៩៥១៤៩៦; ក្រុងព្រះសីហនុៈ ០៣៤ ៩៣៣៧១៦; ស្វាយរៀងៈ ០៤៤ ៩៤៥៨៣៣; តាកែវៈ ០៣២ ៩៣១៣៦០ ។*

សេចក្តីស្រឡាញ់ដល់កូន និងឲ្យតម្លៃដល់គេនោះ គឺគ្រប់គ្រាន់ណាស់ទៅហើយនៅក្នុងករណីនេះ ។ ក្នុងការធ្វើបែបនេះ គេនឹងដឹងថាក្រុមជំនុំគឺជាកន្លែងផ្តល់នូវការប្រោសឲ្យជាពីស្នាមរបួសដួងចិត្ត និងជាកន្លែងដែលមានគេទទួលរាប់អាន ហើយកុមារក៏បានទទួលនូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ តាមរយៈក្រុមជំនុំនៃគ្រួសាររបស់គេ ។

## សហគមន៍

- ចូរប្រាប់អ្នកជិតខាងរបស់លោកអ្នក ប្រធានភូមិ ចៅសង្កាត់ និងអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងសហគមន៍នោះ ឲ្យគេបានដឹងពីបញ្ហា តែត្រូវនិយាយប្រាប់ដោយរើសរកវិធីដ៏សមរម្យដូចមុនទៀត ប្រាប់រឿងរ៉ាវដែលនិយាយតៗគ្នា ប្រាប់ពីរឿងពិត និងប្រាប់ពីឥទ្ធិពលដែលប៉ះពាល់ដោយសារការចាប់រំលោភនោះ ។ បន្ទាប់ពីគេបានយល់នូវបញ្ហានោះហើយ គេអាចចូលរួមជាមួយលោកអ្នកក្នុងការទប់ស្កាត់ និងគាំទ្រដល់កុមារដែលរងគ្រោះដោយសារគេចាប់រំលោភនោះ ។
- ចូរឃ្លាំមើលកុមារនៅក្នុងសហគមន៍របស់លោកអ្នក ដោយជួយមើលថែគេដោយមិនឲ្យគេប្រថុយគ្រោះថ្នាក់ដោយការចេញដើរហើរទៅណាមកណាតែម្នាក់ឯងនៅកន្លែងដែលស្ងាត់ ឬដោយការចេញដើរលេងជាមនុស្សប្រុស ឬយុវជនដែលគួរឲ្យសង្ស័យនោះ ។
- បើលោកអ្នកបានឮថា មានកុមារណាម្នាក់ត្រូវគេចាប់រំលោភ ចូរពិភាក្សាដោយសម្ងាត់ជាមួយកុមារនិងឪពុកម្តាយរបស់នាង ស្តីពីរបៀបដែលត្រូវរាយការណ៍ប្រាប់ទៅនគរបាល ប្រាប់ទៅអង្គការសិទ្ធិមនុស្សនានា ដូចជា អង្គការ *លីកាដូ* ឬអង្គការក្រៅរដ្ឋាភិបាល

ដទៃទៀតដែលធ្វើការជាមួយស្ត្រី ឬកុមារ ។ ចូរអនុញ្ញាតឲ្យពួកគេបាន
ដឹងថា ជំនួយផ្នែកច្បាប់ និងផ្នែកសង្គមគឺគេអាចរកបានតាមរយៈ
អង្គការទាំងអស់នោះ ហើយសូមលើកទឹកចិត្តដល់គេឲ្យស្វែងរក
យុត្តិធម៌ និងជួយការពារដល់កុមារដទៃទៀត ដោយការធ្វើពាក្យ
បណ្តឹងចោទប្រកាន់លើជនល្មើសដែលបានប្រព្រឹត្តការនោះ កុំឲ្យថ្ងៃ
ក្រោយគេប្រព្រឹត្តការដដែលនេះតទៅទៀត ។
ការនេះម្តងទៀតគឺជាការសំខាន់បំផុត គឺត្រូវបង្ហាញនូវសេចក្តី
ស្រឡាញ់ និងការទទួលរាប់អានចំពោះជនរងគ្រោះដែលត្រូវគេចាប់
រំលោភនៅក្នុងសហគមន៍របស់លោកអ្នក ដោយមិនមានការនិយាយ
ខ្សិបខ្សៀវអំពីរឿងអាស្រូវរបស់គេ ឬក៏ធ្វើអ្វីមួយដែលនាំឲ្យគេមាន
ការអាម៉ាស់ ឬបាត់បង់តម្លៃថ្លៃថ្នូរនោះឡើយ ។ ចូរឲ្យតម្លៃដល់គេដូច
ដែលលោកអ្នកផ្តល់តម្លៃដល់កុមារដទៃដែរ ដ្បិតព្រះជាម្ចាស់
ស្រឡាញ់កុមារទាំងអស់ដោយឥតលក្ខខ័ណ្ឌ មិនថាឡើយកុមារនោះ
មានបញ្ហាអ្វីកើតឡើងឡើយ ។

នៅក្នុងការសរុបសេចក្តី ក្នុងនាមយើងគ្រីស្ទបរិស័ទដែលប្រកប ដោយគតិបណ្ឌិត អំណោយទាន និងដោយជំនឿ យើងទាំងអស់គ្នាជាមនុស្ស ដែលប្រុងជើងការនៅក្នុងការទប់ស្កាត់កូនរបស់យើងពីការទទួលរងគ្រោះ ដោយសារការចាប់រំលោភ ហើយយើងត្រូវតែមានសេចក្តីស្រឡាញ់ និងផ្តល់ នូវការគាំទ្រជនរងគ្រោះនៅក្នុងតំណាក់ការដែលជនរងគ្រោះកំពុងតែខំតាំង ជំហរឡើងវិញ ។ បើសិនយើងចេះប្រាប់ពីពត៌មានផ្សេងឲ្យគេដឹង ធ្វើការនោះ ដោយប្រុងប្រយ័ត្ន និងដោយការប្រុងជើងការ ព្រោះវាជារឿងងាយនឹងប៉ះ ពាល់ផ្លូវចិត្ត ហើយព្រមទាំងសុំជំនួយពីព្រះអម្ចាស់នៅក្នុងកិច្ចខំប្រឹងប្រែង របស់យើង នោះយើងអាចធ្វើការនេះទៅបានដោយអាងលើអំណាចចេស្តា និងព្រះគុណរបស់ព្រះអង្គ ។